# TRmaMEtdwgv

## When I learned about it

LIN Lanin

LIn. LanIn

កញ្ញាកើតនៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៨៤ នៅក្រុងភ្នំពេញ។ បច្ចុប្បន្ន កញ្ញាជានិស្សិត ឆ្នាំទី៣ផ្នែកនីតិសាស្ត្រ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ កំណាព្យ «ទម្រាំតែដឹង» ជាស្នាដៃដំបូងរបស់កញ្ញា។

នឹកឡើងសែនខ្វាស
ខាតបង់ទាំងចិត្ត

រឿងអតីតចាស់
ខាតបង់ទាំងប្រាណ
ស្លាកស្នាមក្រឡៅ។

បំភ្លេចមិនបាន
ឥឡូវជិតជាម

យប់ក៏បន្លាច
ខ្ញុំខុសខ្លួនឯង

ថ្ងៃក៏អោយខ្លាច
អោយកើតអាស្រូវ
គ្មានអ្នកគាំទ្រ។

រឿងដែលហួសទៅ
ព្រោះដើរខុសផ្លូវ

គេយល់ថាខុស
គេអោយថយក្រោយ

ខ្ញុំមិនដូច្នោះ
តែខ្ញុំបន្ត
ជីវិតខ្លួនឯង។

បែរគិតថាល្អ
គួរអោយកករ

គេខំជួយឃាត់
គិតថាជីវិត

តែខ្ញុំអនុវត្ត
ពិតលែងចំបែង
ពិតមិនអផ្សុក។

រូបមន្តជាក់ស្តែង
មានគ្នាប្រលែង

លេងថ្នាំផឹកស្រា
អ្នកណាទៅជឿ

គ្រប់បនគ្រប់បារ
ថានឹងកើតទុក្ខ
លែងស្គាល់ខ្លួនឯង។

ពិតមានក្តីសុខ
បើខ្ញុំស្គាល់សុខ

ពុកម៉ែបារម្ភ
មិនភ្ញាក់គំនិត

ខំដាស់តឿនខ្ញុំ
មិនគិតប្រឹងប្រែង
ហូរទឹកនេត្រា។

ទាំងសោកសង្រេង
អោយឪម៉ែឯង

ខ្ញុំបែរជាខុស
ពីដើមខ្ញុំជឿ

កើតជាកំហុស
ប្រុសជាសង្សារ
អោយខ្ញុំរីងរៃ។

បន្ទោសអ្នកណា
ថាមិនសារ៉ា

បានគ្នាមិនយូរ
សន្យាគេភ្លេច

ចិត្តប្រុសក៏ប្តូរ
ព្រោះគ្មានតំលៃ
យកស្រីដូចខ្ញុំ។

បែរមានអ្នកថ្មី
គេថារឿងអី

| | | |
|---|---|---|
| ជ្រុលប៉ុណ្ណោះហើយ | ធ្វើចិត្តអោយស្បើយ | កុំទៅបារម្ភ |
| រកថ្មីមួយទៀត | ធ្វើជាទ្រនំ | ក្រែងគេថែខ្ញុំ |
| | សុខុមជាងមុន។ | |
| ថ្ងៃដេកយប់ដើរ | ជួបមិត្តជួបភ្លើ | ស៊ីផឹកតាមធន |
| ថ្ងៃខ្លះស្រវឹង | ភ្លេចខ្លួនឡើងទន់ | គេបីគេពន់ |
| | មិនដឹងអ្នកណា។ | |
| សប្បាយម្លឹងៗ | ខ្ញុំម្ដេចនឹងដឹង | ថានឹងខ្មោចផ្សា |
| ម៉ោងត្រូវចូលរៀន | បែរគេចសាលា | កុហកម៉ាក់ប៉ា |
| | ថាខ្ញុំមករៀន។ | |
| ជួបគ្រូៗសួរ | ខ្ញុំយកគាប់គួរ | ថាពេលវាគ្មាន |
| សូមពឹងលោកគ្រូ | កែអវត្តមាន | អែបចូលកោះកៀន |
| | ជូនគ្រូតិចតួច។ | |
| សង្សារថ្មីខ្ញុំ | ជាពួកបងធំ | ឆក់ប្លន់បាញ់លួច |
| បានមកសប្បាយ | ចាយអោយតែរួច | សំដីគាត់ស្រួច |
| | លើភ្លើទាំងអស់។ | |
| ក្នុងហ្វូងអ្នកលេង | មានសុទ្ធតែក្មេង | សាច់ឈាមស្រស់ៗ |
| មានអ្នកញៀនថ្នាំ | ទាំងស្រីទាំងប្រុស | ដេករួមចំរុះ |
| | ពិតចុះសម្រុង។ | |
| ខ្ញុំមិនស្ដាប់ទេ | ខ្ញុំមិនខ្វល់ទេ | ខ្លួនកាន់តែលង់ |
| គេមើលមកខ្ញុំ | ថាជាមនុស្សល្ងង់ | អោយល្អផ្លូវផង់ |
| | បែរចង់សាបសូន្យ។ | |
| ឪមិនដាច់ចិត្ត | ម៉ែនៅអាណិត | គិតថាជាកូន |
| មិនចង់ឈរមើល | ឃើញថ្ងៃកូនសូន្យ | រិះរកគ្រប់ក្បួន |
| | អោយកូនត្រឡប់។ | |
| អោយអ្វីគ្រប់យ៉ាង | អោយតែព្រមសាង | កែខ្លួនបញ្ចប់ |
| ម៉ែនៅស្រលាញ់ | ឪពុកមិនស្អប់ | តែខ្ញុំមិនឈប់ |
| | តើធ្វើយ៉ាងណា? | |

គាត់អស់ផ្លូវកែ
ឈប់រាប់រកខ្ញុំ

ខឹងលែងថ្នមថៃ
លែងចង់ត្រូវការ
រហូតតទៅ។

បែរជាកាត់កាល
ខ្ញុំត្រូវបាតផ្សារ

ខ្ញុំមិនឈឺឆ្អាល
ខ្ញុំមិនស្តាយក្រោយ

មិនទៅឈឺក្បាល
ព្រោះខ្លួនល្ងង់ខ្លៅ
ជារាត្រីចរ។

មិននៅសោកសៅ
នៅដើរលើផ្លូវ

អស់ទាំងគ្រួសារ
ព្រោះខ្ញុំញៀនថ្នាំ

អស់ទាំងសង្សារ
មានអ្វីបន្ត
ធ្វើជាផ្កាមាស។

ព្រោះខ្ញុំលែងល្អ
មានតែត្រដរ

ខ្ញុំឈ្លក់ភ្លើងពណិ
ដើរជិតអ្នកល្អ

ភ្លេចអស់គុណធមិ
គេស្អប់គេជៀស
តែពេលរាត្រី។

ប្រែអាស្រូវភាស
ខ្លួនជាផ្កាមាស

ដល់ថ្ងៃដុនដាប
រកគេពឹងពាក់

ទឹកមាត់ក៏សាប
គេមិនប្រណី
រស់ជិតឪម៉ែ។

ខ្លួនអស់តំលៃ
ទើបនឹកឃើញថ្ងៃ

ដេកស្រក់ទឹកភ្នែក
ស្រែកអោយព្រះជួយ

តឹងទ្រូងស្ទើរបែក
ក៏មិនបានដែរ
ខ្ញុំប្រលែងភ្លើង។

ចង់រកផ្លូវកែ
នេះក៏ព្រោះតែ

ម៉ែប្រាប់ថាក្តៅ
ខ្ញុំអកត្តញ្ញូ

ពុកថាកុំទៅ
កំហុសរាប់ម៉ឺន
អោយដើរផ្លូវខុស។

ខ្ញុំនៅតែឆ្អើន
ព្រោះតែភ្លើតភ្លើន

ស្តាយឪស្តាយម៉ែ
ម៉ែឪថ្នមចិត្ត

ដែលខំថ្នមថៃ
មិនដែលបន្ទោស
អោយគាត់សោកា។

ស្តាយរូបសម្រស់
ខ្ញុំបែរជាខុស

ទោះជាខុសអ្វី
អប់រំប្រដៅ

គាត់មិនស្រដី
ក្នុងផ្លូវមេត្តា
ចិត្តគាត់ជាព្រះ។

មិនយកទោសា
ទើបតែដឹងថា

ពេលនេះដឹងខុស ទទួលកំហុស កូនសុំសំពះ
គាត់មិនដាច់ចិត្ត មិនចង់យកឈ្នះ តាំងចិត្តជាព្រះ
នៅតែខន្តី។

ព្រោះកូនល្ងង់ខ្លៅ ពីថ្ងៃនេះទៅ សូមលោកអភ័យ
សូមសាងខ្លួនល្អ សាងជីវិតថ្មី តែមិនដឹងអី
កម្មតាមចងពៀរ។

សាច់ឈាមស្រស់ៗ មិនគួរណាសោះ បែរមានរោគា
អេដស៍ដ៏សាហាវ ធ្វើអោយវេទនា គ្មានទេថ្ងៃជា
កូនពិតជាស្លាប់។

ឆ្លងពីអ្នកណា? ព្រះអើយម្ដេចចារ អោយខ្ញុំឈឺចាប់
ប្រុសៗគគោក មិនអាចរ៉ាយរ៉ាប់ ត្រូវខ្ញុំសម្លាប់
អោយស្លាប់រួមគ្នា។

ម៉ែឪខ្លោចចិត្ត ទួញយំអាណិត ជីវិតបុត្រភ្ងារ
គិតថាបានល្អ រីករាយនឹងគ្នា ឥឡូវបែរជា
ត្រូវព្រាត់ទៅវិញ។

ដប់ប្រាំបួនឆ្នាំ ក្រោមការថែទាំ មិនដែលទោម្នេញ
ថ្នាក់ថ្នមល្ហងលោម ដោយក្ដីស្រលាញ់ ខ្ញុំសងគុណវិញ
អោយលោកទុក្ខា។

ដឹងថាលោកព្រួយ ព្រោះតែខ្ញុំមួយ តែមិនវាចា
ធ្វើម្ដេចជាកូន លោកធ្លាប់រក្សា បីបាច់មេត្តា
ស្មើនឹងជីវិត។

ត្រឹមមួយភ្លែតសោះ អោយខ្ញុំឆ្គងខុស ប្រែជាល្ងង់ល្ងិត
ស្ដាយអើយសែនស្ដាយ មិនគួរប្រព្រឹត្ត ធ្វើអោយជីវិត
វិប្បដិសារី។

កុំត្រាប់តាមខ្ញុំ ខ្លួនតូចចិត្តធំ ពុំគួរគប្បី
ទោះខំស្ដាយក្រោយ ក៏គ្មានថ្ងៃថ្មី អ្វីៗអស់ន័យ
ដោយដៃខ្លួនឯង។

នេះជារឿងពិត　ធ្វើអោយជីវិត　ពិតគ្មានអ្វីថ្លៃង
លោកប្រាប់អោយទៅ　ផ្លូវភ្លឺចិញ្ចែង　បែរល្ងង់ខ្លួនឯង
ដើរផ្លូវងងឹត។

ខ្ញុំខុសទៅហើយ　ឱបងប្អូនអើយ　កុំលង់គំនិត
សប្បាយមួយថ្ងៃ　ទុក្ខមួយជីវិត　ចូរអ្នករិះគិត
យកផ្លូវមួយណា?

ពួកម៉ាកពួកភឿន　ហាក់បន្ថែមល្បឿន　អោយឆាប់ខ្លោចផ្សា
បើមិត្តនាំរៀន　កុំចោលឡើយណា　គេនាំថ្លៃថ្លា
អោយយើងខ្ពង់ខ្ពស់។

ផ្ដាំទៅបងប្អូន　ទាន់ខ្ញុំមិនសូន្យ　ជីវិតនៅរស់
មិនយូរប៉ុន្មាន　អស់អ្នកសង្គ្រោះ　ស្លាប់ទៅក្នុងឈ្មោះ
ព្រោះអេដស៍ប្រល័យ។

ទឹកភ្នែកចុងក្រោយ　ប្រគល់ទៅអោយ　អ្នកមានគុណក្រៃ
កូនសូមអរគុណ　ទឹកចិត្តប្រពៃ　ថ្នាក់ថ្នមបមបី
ដល់ក្ស័យសង្ខារ។

បើមានជាតិមុខ　សូមអោយបានសុខ　កុំបីខ្លោចផ្សា
ផ្សងជួបឪម៉ែ　កុំព្រាត់ទៅណា　កូនសូមសច្ចា
ថាគ្មានទៀតឡើយ។

បើមានទោសពៃ　សូមលោកប្រណី　ថាស្ដីអោយហើយ
អោយយល់កំហុស　អោយដឹងចំលើយ　កុំអភ័យឡើយ
នឹងមនុស្សដូចខ្ញុំ។

ធ្វើអោយលោកព្រួយ　បែរជាមិនជួយ　ការងារតូចធំ
អ្វីៗហួសអស់　ខំសាងសន្សំ　ជាកម្មពៀរខ្ញុំ
ឬក៏យ៉ាងណា?

ទើបដឹងខុសផ្លូវ　លង់ខ្លួនយ៉ាងជ្រៅ　ជីវិតឥតការ
ចង់អោយត្រឡប់　បញ្ចប់បញ្ហា　ជ្រុលអស់អាត្មា
ទម្រាំតែដឹង!